ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# សាមគ្គីកថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ

( ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្ដីគោរព )

វេលានេះ អាត្មាភាពសូមសម្ដែងអំពីដើមកំណើតនៃសន្តិសុខក្នុងលោក ជាសង្ខេប តាមកាលវេលា ដូចមានសេចក្ដីតទៅនេះ ៖

**សុខា សង្ឃស្ស សាមគ្គី** សេចក្ដីព្រមព្រៀងគ្នារវាងពួកក្រុម ជាហេតុនាំឲ្យកើតសន្តិសុខក្នុងលោក ។

ព្រះពុទ្ធភាសិតនេះ មានសេចក្ដីដែលគួរលើកមកអធិប្បាយ ៣ បទ គឺ សាមគ្គី ១ បទ សង្ឃ ១ បទ និងសុខៈ ១ បទ ។

សាមគ្គី ប្រែថា « សេចក្ដីព្រមព្រៀងគ្នា ដំណើរស្រុះស្រួលមូលមិត្តនឹងគ្នា រួបរួមគ្នា ចងបាច់គ្នា ពួតដៃគ្នា វេញគំនិតចូលគ្នា មានចិត្តស្មើគ្នា មានអធ្យាស្រ័យត្រូវគ្នា ទុកចិត្តគ្នា មិនបែកចិត្តពីគ្នា មានចិត្តស្មោះស្មគ្ររកគ្នា មានករណីយកិច្ចត្រូវគ្នា ចុះចិត្តស៊ប់ដូចគ្នា ចុះសម្រុងគ្នា មានមេត្រីចិត្តរលាយចូលគ្នាដូចជាទឹកនិងទឹក ឥតទាស់ទែងខ្វែងគំនិតគ្នា មិនប្រកួតប្រកាន់គ្នា មិនចងគំនុំគ្នា » ។

សង្ឃ ប្រែថា « ពួក ក្រុម ប្រជុំ ហ្វូង បន គណៈ កាយ សង្គម ឬបរិស័ទ » ។ តែបើតាមព្រះវិន័យវិញ លោកសំដៅយកភិក្ខុតាំងពី ៤ រូបឡើងទៅ ហៅថា សង្ឃ ។

សុខៈ ប្រែថា « សេចក្ដីសប្បាយរីករាយ ធម្មជាតទទេសោះតែជារបស់គួរប្រាថ្នា – គួរស្រឡាញ់ ដំណើរស្រួល ស្រណុក មិនរឹករវ មិនជ្រួលច្របល់ មិនក្រវល់ក្រវាយ មិនរកាំចិត្ត មិនក្ដៅក្រហាយ មិនស្ដាយក្រោយ ជាដើម គឺសេចក្ដីសម្រាន្តយ៉ាងស្រួល ។ តែក្នុងទីនេះ សំដៅយកសន្តិសុខ គឺសេចក្ដីសុខស្ងប់ ឬសន្តិភាពដែលជាទីប្រាថ្នារបស់លោកទាំងមូល ។

កាលបើរួបរួមសេចក្ដីប្រែនៃព្រះពុទ្ធភាសិតទាំង៣បទនេះ ចងឲ្យទៅជាប្រយោគមួយទៅ សឹងឃើញច្បាស់ថា សន្តិសុខដែលជាទីស្រឡាញ់ពេញចិត្តរបស់លោកទាំងមូល នឹងកើតឡើងយ៉ាងងាយមិនចាំបាច់វិនិច្ឆ័យរកផ្លូវដទៃក្រៅអំពីសាមគ្គីនេះឡើយ ។

### សាមគ្គីនេះ ចែកចេញជា ៣ យ៉ាងគឺ ៖

១. **កាយសាមគ្គី** សេចក្ដីស្រុះស្រួលព្រមព្រៀងគ្នាដោយកាយ ១

**២. វចីសាមគ្គី** សេចក្តីស្រុះស្រួលមូលមាត់គ្នាដោយពាក្យសម្តី ១

**៣. ចិត្ត-មនោសាមគ្គី** សេចក្តីព្រមព្រៀងស្រុះស្រួលមូលគំនិតគ្នាខាងផ្លូវចិត្ត ១ ។

ការស្រុះស្រួលរួមរក្សារាប់រកគ្នាទៅវិញទៅមករវាងពួកគណៈ ឬសង្គម រហូតដល់លោកជាទីបំផុត មិនប្រេះឆាបែកបាក់គ្នាជាពួកបក្សគណៈនិកាយ រមែងជាបច្ច័យឲ្យបានទទួលនូវសន្តិសុខ និងសេចក្តីចម្រើនរុងរឿងឥតអាក់ ឥតមានឧបសគ្គអ្វីមួយមករារាំងបានឡើយ ។

សាមគ្គីនេះឯង ទុកជាកម្លាំងមួយយ៉ាងសំខាន់ ដែលអាចជួយសាសនា ប្រទេសជាតិ និងលោកទាំងមូលឲ្យបានចម្រើនជាប់មាំបិតថេរ មិនឲ្យត្រឡប់រៀវរោយឬវិនាសទៅបាន បើសាសនិកជនឬប្រទេសជាតិណាមានសាមគ្គីធមិចម្រុងចម្រើនដុះដាល ឬក៏តាំងនៅជាប់មាំល្អហើយ សាសនិកជនឬប្រទេសជាតិនោះ រមែងបានទទួលសេចក្តីសុខដ៏ថ្កុំថ្កើងរុងរឿងយ៉ាងអស្ចារ្យ ឥតមានអំណាចអ្វីចូលទៅលុកលុយឲ្យសាបសូន្យរលាយរលត់បានឡើយ ប្រៀបដូចជាសរសៃអំបោះតូចឆ្មារ ប្រសិនបើគេយកច្រើនសរសៃទៅវេញត្របាញ់ ឬត្រកួញចូលជាមួយគ្នា គេអាចយកសសៃអំបោះនោះទៅចងសត្វទាំងឡាយមានដំរីជាដើម ដែលសត្វមានកម្លាំងច្រើនឲ្យជាប់បាន សត្វទាំងនោះ មិនអាចនឹងទាញរើឲ្យដាច់ខ្សែអំបោះនោះបានឡើយ ។ សូម្បីរូបកាយយើងទៀតសោត ដែលនឹងតាំងនៅឬនឹងចម្រើនឡើងបាន ក៏ដោយសារអាស្រ័យសាមគ្គីរបស់ធាតុទាំង៤ អាការ៣២ និងសរីរាវយវៈដ៏សេសក៏ដូច្នោះដែរ បើរបស់ទាំងនេះមិនរួបរួមឬមិននៅជួបជុំគ្នា ពុកផុយ ឬក៏បែកចែកកម្លាំងគ្នាហើយ រូបកាយយើងក៏មិនអាចប្រព្រឹត្តទៅឬចម្រើនឡើងបានឡើយ ។ នៅក្នុងព្រៃមានសត្វចតុប្បាទ ១ ពួកមាឌតូច ៗ ហៅថា សុនខព្រៃ មាឌតូចជាងសុនខស្រុកទៅទៀតតែមានសាមគ្គីស្រុះស្រួលគ្នាជាទីបំផុត វាអាចទៅចោមរោមខាំសត្វទាំងឡាយ មានខ្លា និងសីហៈជាដើម ដែលជាសត្វមានមាឌធំសម្បើមហើយកាចសាហាវយ៉ាងក្រៃលែង យកទៅធ្វើជាអាហាររបស់វាបាន សត្វខ្លានិងសីហៈជាដើមតែងមានភ័យដ៏ពន្លឹកអំពីពួកសុនខព្រៃជានិច្ច ។ ស្រមោច សង្ហារ កណ្តៀរ ឃ្មុំ និងម្រោមជាដើម វាអាស្រ័យធមិសាមគ្គីស្រុះស្រួលរួមរក្សារាប់រកគ្នា បានជាវាអាចញ៉ាំងកិច្ចគ្រប់យ៉ាងឲ្យសម្រេចតាមបំណងបាន ទាំងនេះក៏ព្រោះអាស្រ័យសាមគ្គីជាហេតុ ។

សុនខព្រៃជាដើម ជាសត្វតិរច្ឆានទាំងមាឌក៏តូចហើយថែមទាំងកាចសាហាវពន់ពេកណាស់ ឥតដែលមានសាសនាណាប្រៀនប្រដៅឥតដែលមានសៀវភៅក្បួនច្បាប់សម្រាប់មើល ទាំងគ្មានអ្នកប្រាជ្ញសម្រាប់ទូន្មានប្រៀនប្រដៅឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យមានសាមគ្គីស្រុះស្រួលគ្នាសោះទេ តែវាចេះបណ្តុះសាមគ្គីស្រុះស្រួលរវាងគ្នាវាបាន ។ ចុះយើងទាំងអស់គ្នាជាមនុស្សជាតិត្រឡាំង មានសាសនាល្អវិសេសសម្រាប់កាន់រក្សា មានក្បួនតម្រាសម្រាប់មើល មានអ្នកប្រាជ្ញយ៉ាងឆ្នើម ៗ សម្រាប់ទូន្មានប្រៀនប្រដៅ ថែមទាំងមានជាតិអ្នកដឹងខុសត្រូវខ្មៅសល្អអាក្រក់ក៏ស្រាប់ ក៏គួរតែបណ្តុះសាមគ្គីឲ្យកើតឡើង កុំឲ្យអន់ថយខ្សោយជាងសត្វតិរច្ឆានមានកណ្តៀរជាដើម ។ កុំប្រើសម្តីលូកលើសើក្រោម ព្រោះជាហេតុនាំឲ្យក្លាយ

ទៅជាទោសវិញទេ ។ ឯការខំប្រឹងប្រែងជួយជ្រោមជ្រែងព្រះពុទ្ធសាសនា នឹងប្រទេសជាតិឲ្យបានចម្រើនឡើងនោះ បើប្រាសចាកទំនងឬប្រាសចាកឧបាយរួបរួមបណ្តុះសាមគ្គីហើយ ក៏មិនងាយនឹងបានសម្រេចប្រយោជន៍តាមបំណងបានឡើយ វត្ថុបំណងនោះនឹងទៅជាអសារឥតការ ។

ក្នុងសម័យឥឡូវនេះ តម្លៃនៃសីលធម៌និងវឌ្ឍនធម៌ ចេះតែរលត់ខ្សត់ខ្សោយរលាយអស់ទៅ នាំឲ្យអស់សេចក្តីសង្ឃឹមក្នុងផ្លូវសន្តិសុខព្រមទាំងវឌ្ឍនធម៌ បើទុកណាជាខំប្រឹងប្រែងស្វែងស្វះរកដោយសតិបញ្ញា ដ៏ល្អិតសុខុមយ៉ាងណាក៏កម្រនឹងធ្វើឲ្យកើតឲ្យចម្រើនឡើងបាន ។ គួរណាស់តែសាធុជនខំប្រឹងធ្វើតាមឲ្យកើតមានឡើង ។

បើតាមច្បាប់ព្រះពុទ្ធសាសនាថា សន្តិសុខក្នុងលោកនេះ នឹងកើតឡើងបានក៏ដោយសារកម្លាំងនៃសាមគ្គីធម៌និងមេត្រីចិត្តដ៏បរិសុទ្ធ ។

ឯការប្រេះឆាបាក់បែកខូចខាតអន្តរាយ ឬវិនាសទៅនៃសាមគ្គីនឹងមេត្រីចិត្តនេះ កើតឡើងដោយសារហេតុច្រើនប្រការ គឺដោយសារឧបក្កិលេសធម៌ ដោយសារអគតិ និងដោយសារទិដ្ឋិជាដើម ។ ឯការប្រេះឆាដោយសារឧបក្កិលេសធម៌នោះ បានដល់ឧបក្កិលេស ១៦ គឺ ៖

**១ – អភិជ្ឈាវិសមលោភៈ** សេចក្តីរំលោភចង់បានហួសទំនង ឬបំពានយករបស់គេមកធ្វើជារបស់ខ្លួន

| | |
|---|---|
| **២ – ទោសៈ** | ប្រទូសរ៉ាយ ផ្តន្ទា បៀតបៀន ឬជិះជាន់គេ |
| **៣ – កោធៈ** | ក្រោធខឹង ឬក៏ធ្វើទុក្ខបុកម្នេញគេ |
| **៤ – ឧបនាហៈ** | ចងពៀរ ចងគំនុំ វេចខ្ចប់នូវកំហឹងទុក |
| **៥ – មក្ខៈ** | លុបគុណ ឃ្មើសគុណ ឬបំភ្លេចគុណគេ |
| **៦ – បលាសៈ** | វាយឫកស្មើ លើកខ្លួនផ្ទឹមនឹងលោក – អ្នកដែលមានបុណ្យសក្តិ ឬចង់ប្រណាំងវាសនា |
| **៧ – ឥស្សា** | ឫស្យា ច្រណែនឈ្នានីសគេ |
| **៨ – មច្ឆរិយៈ** | សេចក្តីកំណាញ់ស្វិតស្វាញ លាក់លៀមទ្រព្យសម្បត្តិរបស់ខ្លួន ឬមិនព្រមចែករំលែកលាភ យស សុខ សរសើរ ប្រយោជន៍ព្រមទាំងអានុភាពនិងសមត្ថភាពដល់អ្នកដទៃ |
| **៩ – មាយា** | មានពុតត្បុតអាក្រក់ ឬបិទបាំងទោសខ្លួនទម្លាក់ទោសរបស់ខ្លួនទៅលើអ្នកដទៃ |
| **១០ – សាថេយ្យៈ** | អួតអាងអែបអប ឬសរសើរលើកគុណដែលមិនមានក្នុង |

ខ្លួនថាមាន

**១១ – ថម្ភៈ** កោងកាច ព្រហើន – រឹងត្អឹង ឬចចេសមុខរឹង

**១២ – សារម្ភៈ** ប្រណាំងប្រជែង ចង់ឈ្នះ ឬដណ្តើមយកព្វកែតែម្នាក់ឯង

**១៣ – មានះ** អួតថាវិសេសជាងគេ លើកកម្ពស់ ឬប្រកាន់ខ្លួនឆ្មើងកន្ទ្រើង ក្រអឺតក្រអោង

**១៤ – អតិមានះ** ចង់ឲ្យខ្ពស់ហួសវិស័យ គឺមើលងាយគេ

**១៥ – មទះ** ស្រវឹងឈ្លក់ ឬប្រកាន់គំនិតក្នុងលាភ យស សុខ សរសើរ

**១៦ – បមាទះ** ធ្វេសប្រហែស លង់ខ្លួន បោះចិត្តទៅក្នុងកាមគុណ ភ្លេចស្មារតី ឬប្រាសចាកសតិសម្បជញ្ញៈ ។

ការប្រេះឆាដោយអគតិគឺការលម្អៀងនោះ បានដល់ **អគតិ ៤ យ៉ាងគឺ ៖**

**១ – ឆន្ទាគតិ** សេចក្តីលម្អៀង ព្រោះយល់មុខ ព្រោះស្រឡាញ់ ព្រោះគាប់ចិត្តថាល្អ ថាប្រសើរ ។

**២ – ទោសាគតិ** សេចក្តីលម្អៀង ព្រោះស្អប់ ព្រោះខឹង មិនពេញចិត្ត ។

**៣ – មោហាគតិ** សេចក្តីលម្អៀង ព្រោះល្ងង់ខ្លៅពុំយល់ការខុស ត្រូវ – ជ្រៅរាក់ ។

**៤ – ភយាគតិ** សេចក្តីលម្អៀង ព្រោះខ្លាចបុណ្យ ខ្លាចអំណាច ខ្លាចធនធាន ឬខ្លាចចិត្តគេ ។

ចំណែកការប្រេះឆាសាមគ្គីដោយទិដ្ឋិ គឺការឈ្វេងយល់ខុសបានដល់ទិដ្ឋិជាសត្រូវធំ២យ៉ាងគឺ ៖

**១ – ឧច្ឆេទទិដ្ឋិ** លទ្ធិមិនជឿស្ថានសួគ៌ នរក មិនជឿបាប បុណ្យ គុណ ទោស អាក្រក់ ល្អជាដើម គិតតែបានថ្កុំថ្កើងរុងរឿងឬសប្បាយក្នុងបច្ចុប្បន្ន ។

**២ – អត្តទិដ្ឋិ** លទ្ធិគិតតែប្រយោជន៍ផ្ទាល់ខ្លួន ពួកបក្ខខ្លួន ឬត្រកូលខ្លួន ។

ធមិជ៌លាមកប៉ុណ្ណេះជាដើម សុទ្ធតែជាឈ្នាន់បំបែកសាមគ្គី ជាមូលហេតុបំផ្លាញសាមគ្គីឲ្យវិនាសអន្តរាយរលត់រលាយសាបសូន្យវិនាសទៅ ។ ហេតុនេះ ពុទ្ធមាមកជនទាំងឡាយគួរតែចៀសវាងឲ្យស្រឡះកុំបណ្តោយឲ្យអកុសលធមិទាំងនោះកើតមានក្នុងសន្តានឡើយ ទើបអាចបណ្តុះសាមគ្គីរវាងសាសនិកជន ឬមនុស្សជាតិផងគ្នាឲ្យកើតឡើងបាន ។ បន្ទាប់ពីនេះនឹងសូមសម្តែងអំពីធមិជាគ្រឿងបណ្តុះសាមគ្គីដូចតទៅនេះ ។

សាមគ្គីដែលនឹងកើតឡើងបាន ឬសូម្បីប្រេះឆាបែកបាក់ទៅហើយនឹងផ្សារតឲ្យជាប់ទៅ

វិញបាន ដោយអាស្រ័យធម៌ច្រើនប្រការគឺ ដោយសារសង្គហវត្ថុ និងសារាណីយធម៌ជាដើម ។ ឯសារាណីយធម៌មិនបានយកមកសម្តែងទេ ព្រោះពេលវេលាដែលត្រូវសម្តែងនៅខ្លីពេក សូមយកតែសង្គហវត្ថុមកសម្តែងតែម្តង ឯ**សង្គហវត្ថុនោះមាន ៤ យ៉ាងគឺ** ៖

**១ – ទានៈ** កាយឲ្យទេយ្យវត្ថុ ឬចែករំលែកអានុភាពនិងសមត្ថភាពដល់គ្នាតាមកាលគួរ ។

**២ – បេយ្យវាចា** ការពោលវាចាគួរឲ្យគេចង់ឮចង់ស្តាប់ ឬឧស្សាហ៍រាក់ទាក់រួសរាយដោយពាក្យពីរោះ ចំពោះជនទូទៅមិនរើសមុខ ឧស្សាហ៍រំឭកដាស់តឿនប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នា ឬពោលពីច្បាប់ទម្លាប់នឹងសេចក្តីខុសត្រូវឲ្យគេបានចេះដឹងដោយសារខ្លួន ។

**៣ – អត្ថចរិយា** ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា ឬធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនព្រមទាំងអ្នកដទៃ ។

**៤ – សមានត្តតា** ការប្រព្រឹត្តខ្លួនឲ្យស្មើ គឺមិនរឹងត្អឹង មិនប្រកាន់ខ្លួនដោយជាតិត្រកូល យសសក្តិ និងទ្រព្យសម្បត្តិ ។

អាត្មាភាពសម្តែងមកអំពីធម៌ជាហេតុឲ្យសាមគ្គីសាបសូន្យវិនាសទៅនឹងធម៌ជាគ្រឿងធ្វើសាមគ្គីឲ្យចម្រើនឡើងនេះ សមគួរដល់វេលានឹងបញ្ចប់ហើយ ។ ដោយអំណាចកុសលដែលកើតអំពីធម្មទេសនានេះសូមឲ្យពុទ្ធបរិស័ទទាំងឡាយកើតមានសាមគ្គីធម៌ឡើង តាំងពីពេលនេះទៅ កុំបីខកខានឡើយ ។

ឯវំ សម្មតា ធម្មទេសនា ការសម្តែងធម៌ សន្មតថាចប់ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះតាមសមគួរដល់កាលវេលា ។


មហា **ឈឹម – មី** សិស្សសាលាបាលីជាន់ខ្ពស់

វត្តសារាវ័នតេជោ សង្កាត់លេខ ៣ ភ្នំពេញ រៀបរៀង

ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ១៩៥៤

Wesite: bvdcc.org

E-mail: chhenchhoun@gmail.com

YouTube: Vipassana Dhurak Buddhist Centre

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាមគ្គីធម៌

វិទ្យុធម្មទេសនា ពីថ្ងៃទី ២៣-៨-៦៦
របស់ភិក្ខុ យឹម-សំអឿន វត្តលង្កា ភ្នំពេញ
ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
ទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំ ១៩៦៦

**នមោ តស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស**

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ
(ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ អាត្មាភាពសូមដកស្រង់យកពុទ្ធភាសិត ថា :" **សុខា សង្ឃស្ស សាមគ្គី** " ប្រែថា " សេចក្តីព្រមព្រៀងគ្នារវាងពួកក្រុមនាំឲ្យកើតសន្តិសុខ(ក្នុងលោក) "ដែលមានសម្តែងជាធម្មាធិដ្ឋានក្នុង ឱវាទប្បាតមោក្ខ" ជាធម្មស្សវនាការ ដូចតទៅនេះ ៖

ពាក្យថា "សាមគ្គី" ប្រែថា សេចក្តីព្រមព្រៀងគ្នា មានចិត្តត្រង់នឹងគ្នា មានករណីយកិច្ចត្រូវគ្នា មិនបែកចិត្តពីគ្នា មានមេត្រីចិត្តរលាយគ្នាទៅវិញទៅមកដូចទឹកនិងទឹក មិនប្រកួតប្រកាន់ មិនចងគំនុំនឹងគ្នា ។

មនុស្ស មាន ២-៣ នាក់ឡើងទៅហៅថា "គណៈ" ។ បើតាមព្រះវិន័យដែលហៅថា "សង្ឃ" នោះ សំដៅយកពួកបព្វជិតដែលមានចំនួនតាំងពី៤រូបឡើងទៅ ។ ប៉ុន្តែ "សង្ឃ" ក្នុងទីនេះប្រែថា ពួក ឬ ក្រុមរបស់ប្រជាជនទូទៅ ។

ពួកជន ដែលទាក់ទងគ្នាដោយត្រកូល ដោយអាជីវៈ(ការចិញ្ចឹមជីវិត)ក្តី ដោយកិច្ចត្រូវគ្នាក្តី ដោយជាតិសាសន៍ជាមួយគ្នាក្តី ដោយសាសនាត្រូវគ្នាក្តី កាលបើមានសាមគ្គី គឺសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះ រមែងជាកម្លាំងធំបំផុតរបស់ពួកក្រុម ឬ ប្រទេសនីមួយៗ ។

ការស្រុះស្រួលគ្នា រាក់ទាក់ចំពោះគ្នាទៅវិញទៅមក ចងគ្នាជាមិត្រសម្លាញ់ ជាបក្សពួកដោយសាមគ្គីធម៌ ដែលមិនបែកប្រេះឆាររវាងគ្នានិងគ្នា រមែងបានទទួលលទ្ធផលដ៏ប្រសើរ គឺសេចក្តីសុខសេចក្តីចម្រើនរុងរឿងជាអចិន្ត្រៃយ៍ ព្រោះហេតុនោះ យើងអ្នកប្រាថ្នាសេចក្តីសុខចម្រើន គួរតែរកឧបាយបង្កើត "សាមគ្គីធម៌" ឲ្យកើតឡើង។

សាមគ្គីធម៌នេះ មិនមែនកើតឡើងដោយឯកឯងទេ ត្រូវតែរកឧបាយបង្កើតទើបកើតឡើងបាន។ ឧបាយដើម្បីបង្កើត "សាមគ្គី" នោះមានដូចតទៅ

*១- ប្រជុំគ្នារឿយៗ តាមកាលបរិច្ឆេទ ដើម្បីពិគ្រោះរកប្រយោជន៍*
*២- ចូលទៅកាន់ទីប្រជុំទាំងលើកលែងទីប្រជុំត្រូវមានសាមគ្គី*
*៣- មិនត្រូវយករឿងដទៃក្រៅអំពីរបៀបវារៈមកនិយាយទេ*
*៤- ត្រូវគោរពស្តាប់គ្នាក្នុងការពិគ្រោះកិច្ចការណាមួយ*
*៥- និយាយការណាមួយ គប្បីវៀរចាកអគតិធម៌*
*៦- ត្រូវរកឧបាយនិយាយឲ្យមានសាមគ្គីធម៌រឿយៗ*
*៧- ត្រូវតាំងខ្លួនគ្រប់ៗគ្នាក្នុងសច្ចធម៌ ទាំងគោរពស្តាប់ប្រធាន*
*៨- ត្រូវនិយាយដោយពាក្យទន់ផ្អែម ទាំងប្រកបដោយសារប្រយោជន៍ ។*

## សាមគ្គីមាន ៣ យ៉ាងគឺ

**១- កាយសាមគ្គី** សេចក្តីព្រមព្រៀងគ្នាដោយកាយ គឺកិច្ចដែលកើតឡើងក្នុងពួករបស់ខ្លួន ត្រូវតែជួយខ្នះខ្នែងដោយកម្លាំងកាយអបស្មបព្រួតគ្នាធ្វើ ដើម្បីញ៉ាំងកិច្ចការនោះៗ ឲ្យឆាប់សម្រេចដូចបំណង។ ម្យ៉ាងទៀតការប្រព្រឹត្តិខ្លួនឲ្យមានសណ្តាប់ធ្នាប់ដោយកាយដែលមានរបៀបរៀបរយដូចគ្នា ហៅថា "កាយសាមគ្គី" ។

**២- វចីសាមគ្គី** សេចក្តីព្រមព្រៀងគ្នាដោយពាក្យសំដី គឺហេតុការណ៍ រឿងរ៉ាវ ឬកម្មវិធីណាមួយដែលត្រូវនិយាយ ដែលត្រូវចាត់ ឬ មិនត្រូវ ក៏ត្រូវតែសន្មតឲ្យមានរបៀបលក្ខណៈដូចគ្នាឈ្មោះថា"វចីសាមគ្គី " ។

**៣- ចិត្តសាមគ្គី** សេចក្តីព្រមព្រៀងគ្នាដោយចិត្ត គឺមានចិត្តជាទីតាំង មានចិត្តប៉ុនប៉ងចំពោះប្រយោជន៍រួម មានចិត្តស្លូតត្រង់ មិនរៀចវេរពីគ្នា ចេះស្រឡាញ់សេចក្តីសុខ-ចម្រើនរបស់ខ្លួន និងពួកគណៈ មិនក្បត់នឹងគ្នា ឈ្មោះថា "ចិត្តសាមគ្គី" ។

ការព្រមព្រៀងគ្នាដោយចិត្តនេះ ជាហេតុមួយជួយបំពេញដល់ កាយ និង វាចា ឲ្យមានសាមគ្គីប្រកបដោយកម្លាំងក្លៀវក្លាឡើង ។ ក៏សាមគ្គីធម៌ទាំង៣នេះឯងហើយ ដែលចាត់ជាពន្លឺមួយសម្រាប់ទ្រោលបំភ្លឺឬ ចាត់ជាកញ្ចប់មួយដ៏មាំ សម្រាប់វេចខ្ចប់នូវឧបាយនៃការបង្កើតសាមគ្គី ឲ្យបានគង់វង្សជាស្ថាពរ។ សាមគ្គីធម៌នេះ បរិបូណ៌ក្នុងទីណាហើយ ទីនោះប្រាកដជាមានសុខសន្តិភាពនិងវឌ្ឍនភាពមិនខានឡើយ។

ករណីយកិច្ចធំៗ ដូចជាការកសាងព្រះវិហារ សាលា អាគារសិក្សា មហាគ្រិះស្ថានជាដើម កាលបើប្រជាជនមានសាមគ្គីធម៌ពេញបរិបូណ៌ហើយ ទៀងតែនឹងញ៉ាំងករណីយកិច្ចនោះៗ ឲ្យសម្រេចបានយ៉ាងឆាប់រហ័សជាប្រាកដ ។ ម្យ៉ាងទៀត សាមគ្គីធម៌នេះ ចាត់ជាកម្លាំងដ៏ធំអាចការពារឧបស័គ្គ គ្រោះថ្នាក់ ភយន្តរាយ មិនឲ្យសត្រូវចូលមកបៀតបៀនបានឡើយ ។ ឧទាហរណ៍ ដូចជា ៖

-សត្វកណ្តៀរ មាឌតូចៗ ប៉ុន្តែវាមានការប្រឹងប្រែងមិនឈប់ នាំគ្នាជញ្ជូនដីពូនជាដំបូកមានកម្ពស់ពីរ-បីជំហរមនុស្ស សម្រាប់ជ្រកកោន ពួនសម្ងំរបស់វាបាន ។

-ផ្លែព្រៃ មានមាឌតូចៗ ជាងផ្លែស្រុកសោះ ប៉ុន្តែវាមានសាមគ្គីនឹងគ្នា បង្កើតជាកម្លាំងមួយ អាចហ៊ានចោមរោមខាំខ្លា រាជសីហ៍ដែលជាម្រឹគធំៗ ដ៏មានអំណាចកាចសាហាវក្រៃលែងយកទៅស៊ីបាន។

ព្រះបរមសម្ពុទ្ធជាម្ចាស់ ទ្រង់ឧស្សាហ៍សម្តែង អំពីសាមគ្គីធម៌នេះចំពោះពុទ្ធបរិស័ទជាញឹកញយណាស់ ទ្រង់សរសើរសាមគ្គីធម៌ថាជាកិច្ចត្រូវបំពេញ ព្រមទាំងអានិសង្សនៃសាមគ្គីធម៌ ដោយអនេកបរិយាយព្រោះហេតុថា សាមគ្គីនេះ ជាគុណជាតិប្រសើរបំផុតក្នុងការស្វែងរកសន្តិសុខដើម្បីប្រទេសជាតិ សាសនារបស់ខ្លួន ។ សាមគ្គីនេះទុកដូចជាស្ពានមុខនៃសន្តិសុខ និងវឌ្ឍនធម៌ ។

ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនដែលសម្តែងសរសើរ អំពីការបំបែកបំបាក់សាមគ្គីថាជាហេតុផ្តល់នូវសន្តិភាព និង វឌ្ឍនភាពសោះឡើយ ។ មានតែទ្រង់សម្តែងបំភ្លឺចំពោះពុទ្ធបរិស័ទ ឲ្យប្រយ័ត្នមិនឲ្យបែកសាមគ្គី ជារឿយៗណាស់ ព្រោះការបែកបាក់សាមគ្គី ជាហេតុមួយនាំឲ្យជាតិ សាសនារបស់ប្រទេសនីមួយៗអន្តរាយវិនាសទៅជាប្រាកដ។ ការបំបែកសាមគ្គីលោកពោលថាជាទោសធំបំផុត។ បណ្តាទោសទាំងអស់ ការញុះញង់បំបែកសាមគ្គី ត្រូវទទួលទោសកំហុសយ៉ាងធ្ងន់ជាងទោសឯទៀតៗ ។ ដូចយ៉ាងទោសអនន្តរិយកម្មទាំង៥ លោកយកទោស"សង្ឃភេទ" (ការបំបែកពួកក្រុម) ថាជាទោសធំបំផុត។ សមដូចពុទ្ធភាសិត ក្នុងគម្ពីរចុល្លវគ្គ វិន័យបិដក ត្រង់សង្ឃភេទក្ខន្ធកៈថា

" អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ
វគ្គរតោ អធម្មដ្ឋោ យោគក្ខេមា បធំសតិ
សង្ឃំ សមគ្គំ ភិន្ទិត្វា កប្បំ និរយម្ហិ បច្ចតិ "

*ប្រែថា " ភិក្ខុអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួកមិនតម្កល់នៅក្នុងធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរកតាំងនៅអស់មួយកប្ប រមែងឃ្លាតចាកធម៌ជាគ្រឿងក្សេមចាកយោគៈ ។ ភិក្ខុអ្នកបំបែកសង្ឃ ដែលកំពុងតែមានសេចក្តីព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរកអស់មួយកប្ប" ។*

សេចក្តីអធិប្បាយបញ្ជាក់ថា ប្រទេសទាំងឡាយនៅលើផែនដី សុទ្ធតែមានច្បាប់សម្រាប់ការពារសន្តិសុខ រវាងជនរួមជាតិនិងជនរួមជាតិ ។ ក្នុងខណៈដែលពួកជន កំពុងមានការស្រុះស្រួលគ្នា នាំគ្នាស្រឡាញ់ប្រទេសជាតិ សាសនា ព្រះមហាក្សត្ររបស់ខ្លួន រួបរួមគ្នារស់នៅក្រោមច្បាប់សម្រាប់ជាតិខ្លួន ហើយប្រសិនបើមានជនណាមួយថ្លស់គំនិត គិតប្រទូសរ៉ាយបំបះបំបោរ បំបែកសាមគ្គីតែជាតិឯង បង្កអសន្តិសុខ ធ្វើឲ្យប្រទេសជាតិអាប់កិត្តិយសរលត់រស្មីទទួលបរាជ័យដោយសារខ្លួនដែលមានចំនួនមួយក្តាប់ ជននោះនឹងត្រូវទទួលទោសយ៉ាងធ្ងន់នៅក្នុងលោកបច្ចុប្បន្ន និង លោកខាងមុខ ជាពិសេសប្រទេសជាតិរបស់ជននោះ នឹងត្រូវទទួល

នូវសេចក្តីលំបាកយ៉ាងចម្លែក គឺត្រូវគេប្រមាថជ្រៀតជ្រែកហែកហួរអំពីប្រទេសដទៃ ព្រោះតែការបែកសាមគ្គីនេះឯង។

ឯការបំបែកបំបាក់ បង្កើតអសន្តិសុខ ធ្វើឲ្យអន្តរាយដល់សាមគ្គីធម៌នេះ កើតឡើងដោយសារហេតុច្រើនប្រការគឺ : ដោយសារឧបក្កិលេស ដោយសារអគតិធម៌ និងដោយសារទិដ្ឋិជាដើម ។ ហេតុទី១ បានដល់៖

**ឧបក្កិលេស ១៦ យ៉ាងគឺ**

១- *អភិជ្ឈាវិសមលោភ:* សេចក្តីលោភ ចង់បានហួសហេតុ បំពារបំពានរំលោភចង់បានតែរបស់គេ ។

២- *ទោស:* ប្រទូស ឬបៀតបៀនគេ ។

៣- *កោធ:* ក្រោធខឹង ធ្វើទុក្ខបុកម្នេញគេ ។

៤- *ឧបនាហ:* ចងគំនុំ ឬ ចងក្រោធទុក ។

៥- *មក្ខ:* លុបគុណ ឬ វេរឃ្មើរគុណគេ ។

៦- *បលាស:* វាយឫកស្មើ លើកតំកើងខ្លួន ។

៧- *ឥស្សា* ឫស្សាច្រណែនឈ្នានីសគេ ។

៨- *មច្ឆរិយ:* កំណាញ់ស្វិតស្វាញ ។

៩- *មាយា* មានពុតត្បុតអាក្រក់ ឬ បិទបាំងទោសខ្លួន ហើយទម្លាក់ទៅលើអ្នកដទៃ ។

១០- *សាថេយ្យ* អួតអាង អែបបន្លំខ្លួន ។

១១- *ថម្ភ:* កោងកាចព្រហើន ចចេសមុខរឹង ។

១២- *សារម្ភ:* អួតថាគ្រាន់ ដណ្តើមពូកែតែឯង ។

១៣- *មាន:* ប្រកាន់ខ្លួន ឆ្មើងកន្ទ្រើង ។

១៤- *អតិមាន:* មើលងាយគេ ប្រមាថបៀតបៀនគេ ។

១៥- *មទ:* ស្រវឹងឈ្លក់ ក្នុងលាភ យស សុខ សរសើរ ។

១៦- *បមាទ:* ធ្វេសប្រហែស ភ្លេចស្មារតី ។

***ហេតុទី ២ បានដល់អគតិធម៌ ៤ យ៉ាងគឺ***

**១- ឆន្ទាគតិ** សេចក្តីលំអៀង ឬ យល់មុខព្រោះស្រឡាញ់ ។

**២- ទោសាគតិ** សេចក្តីលំអៀង ឬ ផ្តន្ទាទោសព្រោះស្អប់ ។

៣- មោហាគតិ     សេចក្តីលំអៀង ឬ កិកកុកព្រោះល្ងង់ ។

៤- ភយាគតិ     សេចក្តីលំអៀង ឬ រណេបរណឹបអែបអបព្រោះខ្លាច ។

### *ហេតុទី ៣ បានដល់ទិដ្ឋិ ឬ សត្រូវធំពីរយ៉ាងគឺ*

១- ឧច្ឆេទទិដ្ឋិ     លទ្ធិមិនជឿឋានសួគ៌-នរក មិនជឿបុណ្យបាប ។

២- អត្តទិដ្ឋិ     លទ្ធិគិតតែប្រយោជន៍ខ្លួនជាតិខ្លួនមិនគិតប្រយោជន៍គេជាតិគេ ។

ធម៌ដ៏លាមកប៉ុណ្ណេះជាដើម សុទ្ធតែឆ្នួនបំបែកសាមគ្គី ជាមេបំផ្លាញសាមគ្គីឲ្យអន្តរាយសាបសូន្យទៅ ។ ដូច្នេះ គួរសាធុជនចៀសវាងឲ្យស្រឡះ កុំបណ្តោយឲ្យធម៌ដ៏ទន់ខ្សោយ ចូលមកដឹកនាំខ្លួនយើង គប្បីយើងឲ្យប្រើឧបាយប្រាជ្ញា ដឹកនាំញាំញីធម៌ទន់ខ្សោយនេះវិញ ទើបអាចបណ្តុះសាមគ្គីរវាងសាសនិក ឬ មនុស្សជាតិផងគ្នាឲ្យកើតឡើងបាន រួចហើយគប្បីខ្នះខ្នែងស្វែងរកធម៌ ដែលនាំឲ្យសាមគ្គី រកឧបាយផ្សះផ្សានូវការបាក់បែកប្រេះឆា ឲ្យជាប់ជិតស្និទ្ធឡើងវិញ ។

សាមគ្គីនឹងកើតឡើងបានឬសូម្បីប្រេះឆាទៅហើយនឹងផ្សាតឲ្យជាប់បាននោះ ដោយអាស្រ័យធម៌ច្រើនប្រការគឺ សង្គហធម៌និងសារាណីយធម៌ជាដើម ។

### *សង្គហធម៌ ៤ យ៉ាងគឺ :*

១- ទាន     ការឲ្យទេយ្យវត្ថុ ឬចែករំលែកអានុភាព និងសមត្ថភាពតាមការគួរ

២- បេយ្យវជ្ជៈ     ការពោលវាចា គួរឲ្យចង់ឮ ចង់ស្តាប់ ឬ ឧស្សាហ៍រាក់ទាក់ដោយពាក្យពិរោះ ចំពោះជនទូទៅមិនរើសមុខ ។ ឧស្សាហ៍រំលឹកដាស់តឿនប្រាប់ប្រយោជន៍ ច្បាប់ទម្លាប់ និងសេចក្តីខុសត្រូវ

៣- អត្ថចរិយា     ការប្រព្រឹត្តិអំពើជាប្រយោជន៍ ដល់គ្នានិងគ្នា ឬ ប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនព្រមទាំងអ្នកដទៃ

៤- សមានត្តភាព     ការតាំងខ្លួនស្មើ ។ មិនរឹងត្អឹង មិនប្រកាន់ខ្លួនដោយជាតិ ត្រកូល យសសក្តិ និងទ្រព្យសម្បត្តិ ។

### *សារាណីយធម៌ ៦ យ៉ាងគឺ*

១- មេត្តាកាយកម្ម ការងារដែលត្រូវធ្វើការតាមផ្លូវកាយ សុទ្ធតែប្រកបដោយមេត្តា ឬ មេត្រីចិត្តដល់គ្នានិងគ្នា

២- មេត្តាវចីកម្ម     កិច្ចការដែលត្រូវចាត់ចែងដោយសំដី សុទ្ធតែប្រកបដោយមេត្តា

៣- មេត្តាមនោកម្ម អំពើដែលធ្វើក្នុងចិត្ត សុទ្ធតែប្រកបដោយមេត្តា

៤- លាភៈ     ការចែករំលែក លាភៈ យស សុខ សរសើរដល់គ្នា

៥- **សីលៈ** ដំណើរមានសណ្ដាប់ធ្នាប់ មានរបៀបបែបបទ និងសេចក្ដីប្រព្រឹត្តិត្រូវគ្នា

៦- **ទិដ្ឋិ** សេចក្ដីយល់ត្រូវ ចុះសម្រុងគ្នា ឬលទ្ធិត្រូវគ្នា ។

ធម៌ដ៏ឧត្ដមប៉ុណ្ណេះជាដើម សុទ្ធតែជាមេ ឬជាបច្ច័យឲ្យកើតសាមគ្គី ទាំងជាគ្រឿងផ្សាសាមគ្គី ដែលប្រេះឆាឲ្យជាប់មាំវិញបាន ។ កាលបើស្វែងរកមេ ឬ ធម៌ជាបច្ច័យឲ្យកើតសាមគ្គី ឬធម៌ជាគ្រឿងផ្សាសាមគ្គីឲ្យកើតឡើងបានហើយ គួរតែស្វែងរកចំណីអាហារ ជគ្រឿងថែរក្សាសាមគ្គីឲ្យមានជីវិតជាសកម្មតទៅទៀត ។

ឯធម៌ជាចំណីអាហារ សម្រាប់ចិញ្ចឹមឃុំគ្រងរក្សាសាមគ្គីឲ្យមានជីវិតលូតលាស់ឡើង ដែលហៅថា "**សាមគ្គីរក្ខា**" នោះមាន ៦ យ៉ាងគឺៈ

១- **វិរិយៈ** សេចក្ដីព្យាយាមក្លៀវក្លា

២- **ខន្តិ** សេចក្ដីអត់ធន់ ឬ តស៊ូ អត់ធ្មត់ចំពោះការងារ

៣- **សច្ចៈ** សេចក្ដីស្មោះត្រង់ដល់គ្នា មិនក្បត់ចិត្តគ្នា

៤- **អធិដ្ឋាន** សេចក្ដីខ្ជាប់ខ្ជួនដោយឧបាយបញ្ញា

៥- **មេត្តា** សេចក្ដីរាប់អានគ្នា ដោយស្និទ្ធស្នាល

៦- **បរិច្ចាគៈ** ការចែករំលែកដោយសង្គ្រោះ ឬដោយបូជាគុណ ។

សាមគ្គីរក្ខាទាំង ៦ យ៉ាងនេះ ទុកដូចជាចំណីអាហារសម្រាប់បំប៉នសាមគ្គី ឲ្យរីកធាត់ធំមានកម្លាំង ពុំនោះទុកដូចជាជីជាតិសម្រាប់ស្រោចស្រង់ប្រស់ព្រំសាមគ្គី ដែលទើបនឹងដុះដាលឲ្យលូតលាស់ ឲ្យរីកចម្រើនឡើង។ ក៏សាមគ្គីនោះឯង បើប្រាសចាកធម៌ទាំងនេះហើយ ក៏រមែងរលត់រលាយ ក្លាយជាស្វិតស្រពោនទៅ ឬ ក៏បែកបាក់រលាយបាត់ទៅដោយឆាប់រហ័សពុំខាន ។ ព្រោះហេតុនោះ សាធុជនអ្នកមានបំណងល្អចំពោះសាសនា ប្រទេសជាតិ និងចំពោះលោកទាំងមូល ចង់ឲ្យបានសន្តិភាព និងវឌ្ឍនភាព រុងរឿងអស់កល្បកប្បនោះ គប្បីតម្កល់ខ្លួនឲ្យតាំងនៅក្នុងឧត្តមធម៌ទាំងអស់ ដូចបានរៀបរាប់មកជាសង្ខេប ទើបសាមគ្គីធម៌ សីលធម៌ វឌ្ឍនធម៌ដុះដាលលូតលាស់ឡើង ហើយចេះតែចម្រើនជាសកម្មតទៅ។

កាលបើជាតិ សង្គមណា មានសាមគ្គីធម៌ សីលធម៌ វឌ្ឍនធម៌ និងអារ្យធម៌ លូតលាស់ហើយ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ទ្រង់សម្ដែងថា *"នឹងត្រូវទទួល នូវ***អានិសង្ស នៃសាមគ្គីរស ៧ យ៉ាង"គឺៈ**

**១- និដ្ឋធម្មេ សមគ្គានំ សុខំ ឧបបជ្ជតិ** សេចក្ដីសុខរបស់ពួកជនអ្នកព្រមព្រៀងគ្នារមែងកើតឡើងក្នុងបច្ចុប្បន្ន ។

**២- ឧត្តរី សព្វា វុឌ្ឍិ ឧបបជ្ជតិ** វឌ្ឍនធម៌គ្រប់យ៉ាង រមែងកើតមានឡើងយ៉ាងក្រៃលែង ។

**៣- ពុទ្ធាទយោ សមគ្គេ បសំ សន្តិ** បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម រមែងសរសើរចំពោះពួកជនដែលព្រមព្រៀងគ្នា ។

**៤- បរេ ជនា ន មទមញ្ញន្តិ** ជនទាំងឡាយដទៃ នឹងមិនហ៊ានមើលងាយ ។

**៥- សមគ្គានំ តាមេ ចោរកម្មំ ន ហោតិ** ចោរកម្ម ក្នុងស្រុករបស់អ្នកព្រមព្រៀងគ្នាមិនមាន ។

**៦- កល្យាណោ កិត្តិសទ្ទោ មព្ភុគ្គច្ឆតិ** កិត្តិសព្ទដ៏ល្អរមែងល្បីល្បាញ ។

**៧- កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** លុះបែកធ្លាយរាងកាយទៅ បន្ទាប់ពីសេចក្ដីស្លាប់ ក៏រមែងទៅកើតក្នុងសួគ៌ទេវលោក ។

ធម៌ទាំង ៧ ប្រការនេះ ទុកដូចជារង្វាន់មួយដ៏មានតម្លៃសម្រាប់ជូនចំពោះពពួកជន ឬប្រទេសជាតិណា ដែលមានសេចក្ដីព្រមព្រៀងគ្នា ។ សមដូចជាប្រទេសវជ្ជី នាសម័យពុទ្ធកាល ដែលមានរបៀបគ្រប់គ្រងជាសាធារណរដ្ឋ ដោយអាស្រ័យធម៌សាមគ្គីជាហេតុ ទើបក្រុងវេសាលី ដែលជារាជធានីនៃដែននោះ ទៅជាក្រុងមួយដ៏រុងរឿងបំផុត មានអារ្យធម៌ល្បីល្បាញផ្សាយទៅគ្រប់ទិសទី ទាល់តែព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រៀបប្រដូចទៅនឹងស្ថានសួគ៌ឈ្មោះចាតុម្មហារាជិកា ទាំងទ្រង់ព្យាករថា ″ បើអ្នកដែនវជ្ជីនៅតែមានសាមគ្គី ប្រព្រឹត្តតាមអបរិហានីយធម៌ដូច្នេះ ដែនវជ្ជីនោះ នឹងចម្រើនរុងរឿងឥតអាក់ ឥតមានប្រទេសណាហ៊ានទៅលុកលុយ ក្នុងផ្ទៃក្នុងបានឡើយ ។

តែគួរឲ្យស្ដាយជាទីបំផុត ដោយសម័យតមក អ្នកដែនវជ្ជីបែកសាមគ្គីគ្នា ទៅជាគណៈបរប័ក្ស បៀតបៀនកាប់សម្លាប់តែគ្នាឯង មិនយូរប៉ុន្មាន ក៏ត្រូវសហរដ្ឋមគធៈ លើកកងទ័ពចូលមកវាយលុកទាល់តែដែនវជ្ជីរលាយរលត់រលប់ឈ្មោះបាត់ពីផែនទីលោករហូតដល់សព្វថ្ងៃ ព្រោះទោសនៃការបែកសាមគ្គីនេះឯង ។

សម្ដែងមកក្នុងពុទ្ធភាសិតថា ″ *សុខា សង្ឃស្ស សាមគ្គី* ″ ប្រែថា ″ សេចក្ដីព្រមព្រៀងរវាងពួកក្រុមនាំ ឲ្យកើតសន្តិសុខ(ក្នុងលោក )″ ក៏សន្មតថាចប់ដោយសង្ខេបតែប៉ុណ្ណេះ។ ធម្មទេសនាតេជេន ដោយតេជៈនៃធម្មទេសនានេះ សូមទេវតាទាំងមួយហ្មឺនលោកធាតុ ពិភក្តិរក្សាសម្ដេចព្រះសង្ឃរាជ ដែលជាព្រះបិតាសង្ឃក្នុងកម្ពុជរដ្ឋ សូមទ្រង់ប្រកបដោយព្រះជន្មាយុទីឃាយុយឺនយូរអស់រយព្រះវស្សា ប្រាសចាកទុក្ខសោករោគាពាធគ្រប់ជំពូក ។ ពិភក្តិរក្សាសម្ដេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ សម្ដេចព្រះប្រមុខរដ្ឋព្រះបិតាសន្តិភាពជាតិ សូមទ្រង់ប្រសិទ្ធិ៍ដោយចតុព្វិធពរ គឺ អាយុ វណ្ណៈ សុខៈ ពលៈ បរិបូណ៌ដោយព្រះសតិបញ្ញាភ្លាហានឲ្យបានលុះដល់ឧត្តមគតិដោយមហុត្តកាល ដ៏រួសរាន់ទាន់សម័យ ទាំងសូមពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដែលបានប្រតិបត្តិតាមសាសនវិធី រួបរួមគ្នារស់ក្រោមអធិបតេយ្យនៃព្រះសម្មាសម្ពុទ្ធឲ្យបានប្រកបដោយសុខភាពអនាម័យដ៏ល្អ ដើម្បីជាពលរដ្ឋប្រកបកិច្ចសាសនា ភ្លាហាន បានមគ្គាភិសម័យសមតាមសមតាមអធ្យាស្រ័យ វត្ថុបំណងកុំបីឃ្លៀងឃ្លាតឡើយ ឯវំ ។